# **ករណីសិក្សា**

## **ស្ដីពី**

"ស្ត្រីក្នុងនាទីជាអ្នកដឹកនាំភូមិគោកដូង ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង"

បងស្រី **យ៉ន យី** អាយុ៤៤ឆ្នាំ រស់នៅក្នុងភូមិគោកដូង ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលមានសមាជិកក្នុងក្រុមគ្រួសារចំនួន៤នាក់ក្នុងនោះមានស្រី៣នាក់ ដែលមានឪពុកអាយុ៦៩ឆ្នាំនិងម្ដាយមានអាយុ៧០ឆ្នាំ និងមានប្អូនស្រី១នាក់ទៅប្រកបមុខរបរដកដំឡូងនៅព្រំដែនខ្មែរ-ថៃ។ សព្វថ្ងៃបងស្រីមានមានមុខរបរធ្វើការងារជាសមាជិកភូមិគោកដូង ឃុំពាមឯក ចាប់តាំងពីឆ្នាំ២០០៦មក ហើយជាមួយនោះដែរបងស្រីក៏មានការងារផ្សេងទៀតផងដែរគឺជាប្រធានសហគមន៍ពន្លឺអភិវឌ្ឍន៍ភូមិគោកដូងចាប់តាំងពីឆ្នាំ១៩៩៧,ជាគណៈកម្មការគ្រប់គ្រងសាលារៀនភូមិគោកដូងនៅឆ្នាំ២០១៣, ជាគណៈកម្មការកិច្ចការនារីនិងកុមារ (គ.ក.ន.ក) របស់ឃុំ,ជាម្ដាយបង្គោលនៅភូមិគោកដូងឆ្នាំ២០១១ដែលមានចំនួន៥ក្រុមស្មើនឹង៣០គ្រួសារស្មើនឹង៣៩កុមារ,ជាគណៈកម្មការត្រួតពិនិត្យនិងតាមដានគ្រួសារកុមារក្នុងគម្រោងឆ្នាំ២០១៣ និងការងារមួយទៀតនោះគឺជាគ្រូបង្រៀនកីឡានៅសាលារៀនគោកដូងឆ្នាំ២០១៣។ ក្នុងការធ្វើការងារជាសមាជិកភូមិបងស្រីបានយកចិត្តទុកដាក់ក្នុងការរៀបចំនូវទិន្នន័យភូមិ,ការធ្វើផែនការប្រចាំឆ្នាំ ការប្រជុំប្រចាំខែនៅសាលាឃុំ ការរៀបចំនូវកម្មវិធីបណ្ដុះបណ្ដាលអំពីអាហារបំប៉នសម្រាប់កុមារក្នុងភូមិ ការដោះស្រាយជម្លោះមានអំពើហឹង្សាក្នុងភូមិ ការប្រមូលបដិភាគក្នុងភូមិដើម្បីប្រមូលថវិកាកសាងនិងជួសជុលផ្លូវក្នុងភូមិជាដើម ហើយជួយផ្សព្វផ្សាយអំពីបញ្ហាសុខភាពក្នុងភូមិដូចជាការចាក់ថ្នាំបង្ការដល់កុមារអប់រំដល់ម្ដាយសំរាលកូន។ល។ ជាមួយនោះផងដែរបងស្រីក៏បានជួយសម្របសម្រួលនិងចាត់ចែងក្នុងកម្មវិធីផ្សេងៗក្នុងភូមិដូចជាបុណ្យក្នុងភូមិជាដើម។ ចំណែកការងារក្នុងសហគមន៍ពន្លឺអភិវឌ្ឍន៍ ភូមិគោកដូងវិញបងស្រី ក៏បានធ្វើការគ្រប់គ្រងទូទៅ ពិនិត្យមើលទៅលើក្រុមសន្សំការផ្ដល់លុយកម្ចី ការធ្វើរបាយការណ៍ ការប្រជុំគណៈកម្មការក្នុសហគមន៍ដើម្បីដោះស្រាយបញ្ហាផ្សេងៗនៅក្នុងសហគមន៍។ ជាមួយគ្នានោះដែរបងស្រីក៏បានបំពេញការងារជាគណៈកម្មការគ្រប់គ្រងសាលារៀនគោកដូងដើម្បីចូលរួមក្នុងការប្រមូលកុមារគ្រប់អាយុឱ្យចុះចូលរៀន និងបានចូលរួមប្រជុំធ្វើផែនការជាមួយលោកមេភូមិ,លោកនាយកសាលា,បុគ្គលិកអង្គការដៃគូរដើម្បីពិភាក្សាអំពីតម្រូវការសាលាដោយប្រជុំ១ខែឬ២ខែម្ដង។ បងស្រីក៏បានធ្វើការងារក្នុងឃុំជាគណៈកម្មការកិច្ចការស្ត្រីនិងកុមារ(គ.ក.ន.ក)ដើម្បីពិនិត្យមើលនិងតាមដានលើការងារនៃការរំលោភបំពានលើស្ត្រីនិងកុមារនិងការជួញដូរស្ត្រីនិងកុមារក្នុឃុំនិងបានចូលរួមប្រជុំរាយការណ៍ក្នុងភូមិ-ឃុំ។ មិនតែប៉ុណ្ណោះទេបងស្រី ក៏បានបំពេញការងារជាម្ដាយបង្គោលនៅក្នុងភូមិដើម្បីធ្វើការប្រជុំ,អប់រំអំពីការនិយាយដល់កុមារឱ្យចេះនិយាយបានច្បាស់លាស់និងការប្រើភាសាល្អៗ



ទៅកាន់អ្នកមានគុណ,ចាស់ព្រឹទ្ធាចារ្យនិងមនុស្សផ្សេងៗទៀតព្រមទាំងបានអប់រំអំពីការយកចិត្តទុកដាក់ទៅលើអនាម័យសុខភាពការហូបចុកទាំងអប់រំដល់ម្តាយនិងកុមារអំពីសិទ្ធិកុមារទាំង៤ឱ្យយល់ដឹង។ បងស្រីក៏បានចូលរួមធ្វើជាគណៈកម្មការត្រួតពិនិត្យនិងតាមដានគ្រួសារកុមារក្នុងគម្រោងរបស់អង្គការវើលវិសហ្សិនកម្ពុជា ដែលចុះតាមដានកុមារតាមគោលដៅក្នុងភូមិដោយផ្តោតសំខាន់ទៅលើការសិក្សារបស់កុមារ និង តាមដានទៅលើការចំណាកស្រុករបស់ឪពុកម្តាយនិងកុមារ ព្រមទាំងធ្វើការពន្យល់ដល់ឪពុកម្តាយនិងកុមារអំពីសារៈប្រយោជន៍នៃការសិក្សារបស់ក្មេង។ ជាមួយគ្នានោះដែរបងស្រីក៏បានចំណាយពេលវេលា១អាទិត្យ១ថ្ងៃហើយចំណាយពេល១ម៉ោងជាគ្រូបង្គោលបង្រៀនកីឡាដល់សិស្សថ្នាក់ទី២ដល់ទី៤នៃសាលារៀនបឋមសិក្សាគោកដូងដោយបង្រៀនអំពីការបោះបាល់, ការត្រេះបាល់, ការបញ្ជូនបាល់ឱ្យគ្នាទៅវិញទៅមកជាដើម ដែលជាគម្រោងរបស់ អង្គការទស្សនៈតតព្រំដែន។ កត្តាដែលជម្រុញឱ្យបងស្រីធ្វើកិច្ចការនោះគឺបងស្រីចង់ឃើញអនាគតភូមិរបស់បងស្រីមានការអភិវឌ្ឍន៍ ចង់ឱ្យក្មេងជំនាន់ក្រោយបានទទួលនូវចំណេះដឹងនិងបានចូលរៀនបានគ្រប់ៗគ្នា និងធ្វើឱ្យក្មេងជំនាន់ក្រោយមានអនាគតភ្លឺស្វាងកុំឱ្យដូចចាស់ជំនាន់មុនដែលមិនបានចូលសាលារៀននិងមិនមានឱកាសទទួលបាននូវចំណេះដឹង មានការគាំទ្រនិងមានការជម្រុញពីក្រុមគ្រួសារព្រមទាំងមានការ



គាំទ្រពីប្រជាជននៅក្នុងឃុំ-ភូមិ និងការទទួលបាននូវចំណូលមួយផ្នែកនិងមានភាពជឿជាក់លើខ្លួនឯង ព្រមទាំងមានការតស៊ូក្នុងជីវិត និងពុះពារគ្រប់ឧបសគ្គ ប្រឈមមុខជាមួយនឹងការរិះគន់ពីសំណាក់អ្នកជិតខាង ដែលថាបងស្រី "*ជាមនុស្សស្រីដែលរៀនបានតិចហើយដឹងចង់ធ្វើការងារធំដុំអីទេ ដាំបាយ ធ្វើការងារបំរើគ្រួសារមិនសព្វផង ចង់ធ្វើការងារធំអីកើតទេ* " តែទោះយ៉ាងណាក៏ដោយបងស្រីមានការតាំងចិត្តតស៊ូធ្វើការងារនោះតាមដំណាក់កាល និងជំហ៊ានរបស់វារហូតដល់បានទទួលជោគជ័យដល់ថ្ងៃនេះ។ បងស្រីបានសំដែងការអរគុណដល់អ្នករិះគន់ទាំងនោះដែលបានធ្វើឱ្យបងស្រីចេះតស៊ូនិងមិនរារថយដែលនាំឱ្យបរាជ័យ "*ដោយសារតែមានការរិះគន់នោះទើបធ្វើឱ្យខ្ញុំមានថ្ងៃនេះ* " បងស្រីខិតខំធ្វើការងារដោយពេញចិត្តណាស់ដោយសារតែចង់ចេះចង់ដឹងពីការងារ ពេលខ្លះការងារពិបាកបងស្រីតែងតែមានអារម្មណ៍ចង់ឈប់ធ្វើការងារនោះម្តងៗតែដោយសារតែបងស្រីមានការតាំងចិត្តខ្ពស់និងមានការតស៊ូនោះទើបធ្វើឱ្យគាត់មិនបោះបង់ចោលការងារនោះ "*ខ្ញុំហ៊ានថា គឺខ្ញុំហ៊ានធ្វើ* " ។ ទោះបីជាមានការងារមួយចំនួនបានទទួលជោគជ័យក៏ដោយក៏បងជួបនូវបញ្ហាមួយចំនួនដូចជា ពុំមានចំណេះដឹងគ្រប់គ្រាន់ក្នុងការរៀបចំការងាររបាយការណ៍ ការសងលុយត្រលប់របស់សមាជិកមិនទាន់ពេលវេលា ការចំណាកស្រុករបស់ឪពុកម្តាយ-កុមារ ការប្រែប្រួលអាកាសធាតុ,សត្វល្អិត ជម្ងឺប្លែកៗ ទោះបីជាមានបញ្ហានេះក៏ដោយបងស្រីតែងតែព្យាយាមដោះស្រាយបញ្ហាជាច្រើន ក្នុងភូមិដោយមានមេភូមិ ឃុំចាស់ព្រឹទ្ធាចារ្យ ចូលរួមដោះស្រាយរៀនរស់ដោយសម្របជាមួយ អាកាសធាតុ ការពន្យល់ណែនាំដោយការលើកទឹកចិត្ត ការផែនការច្បាស់លាស់

និងចេះវិភាគពិចារណាលើការងារបានត្រឹមត្រូវ។ មិនតែប៉ុណ្ណោះទេបងស្រីតែងតែមានទំនាក់ទំនងល្អជាមួយអង្គការដៃគូរដែលបានជួយអភិវឌ្ឍន៍នៅក្នុងភូមិ-ឃុំដើម្បីជម្រុញឱ្យភូមិ-ឃុំមានការអភិវឌ្ឍន៍និងរីកចំរើនជាលំដាប់។

ជាចុងក្រោយបងស្រីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកមេឃុំ-មេភូមិ លោកគ្រូ អ្នកគ្រូ ចាស់ព្រឹទ្ធាចារ្យ ប្រជាជនគ្រប់មណ្ឌដ្ឋានជុំវិញ ដែលតែងតែជួយជម្រុញនិងលើកទឹកចិត្តដល់រូបខ្ញុំក្នុងការធ្វើការងារឱ្យទទួលបានជោគជ័យរហូតដល់មានថ្ងៃនេះ។ ជាពិសេសក៏សូមថ្លែងអំណរគុណដល់អង្គការអភិវឌ្ឍន៍ស្ត្រី ក៏ដូចអង្គការនានាដែលបានជួយបណ្តុះបណ្តាលនិង រៀនសូត្រព្រមទាំងបានបញ្ជូនទៅទស្សនៈកិច្ចសិក្សា ដកស្រង់បទពិសោធន៍ពីគ្នាទៅវិញទៅមកនៅកន្លែងផ្សេងៗ ដើម្បីយកមកជួយអភិវឌ្ឍន៍នៅភូមិ-ឃុំយើងខ្ញុំនេះឱ្យមានការរីកចំរើនពីមួយថ្ងៃទៅមួយថ្ងៃ៕